# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៤៣៨...អនក្រ.តត

## អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងអ្នកសម្របសម្រួលជាតិទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរបស់រាជរដ្ឋាភិបាលកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្ត ទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០១៣ អនក្រ.តត ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការតែងតាំងរដ្ឋមន្ត្រី ទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ
- បានឃើញអនុក្រឹត្យលេខ ៤៦៨ អនក្រ.តត ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីការតែងតាំងរដ្ឋមន្ត្រី ទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ
- បានឃើញអនុក្រឹត្យលេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការតែងតាំងតំណាងជាតិទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំងនិងប្រគល់ភារកិច្ចបន្ថែមលើមុខងារបច្ចុប្បន្នជូនឥស្សរជន ដូចមានរាយនាមខាងក្រោម÷

១. ឯកឧត្តម **សុខ ចិន្តាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជារដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ។

២. ឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកសម្របសម្រួលជាតិនៃកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ និងជាប្រធានលេខាធិការដ្ឋានជាតិមហាអនុតំបន់មេគង្គ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ មានភារកិច្ចដូចតទៅ÷

ក. ទទួលខុសត្រូវក្នុងការសម្របសម្រួល និងដឹកនាំការងារក្នុងក្របខណ្ឌកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ ជាមួយនឹងប្រទេសជាសមាជិកដទៃទៀត និងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងដៃគូអភិវឌ្ឍន៍ដទៃទៀតដែលមានការពាក់ព័ន្ធ។

ខ. ដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីមហាអនុតំបន់មេគង្គ។

គ. ត្រួតពិនិត្យ តាមដាន និងប្រមូលសរុបការអនុវត្តគម្រោងសហប្រតិបត្តិការនានានៅក្នុងក្របខណ្ឌកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ។

ឃ. រាយការណ៍ជាប្រចាំ អំពីការងាររបស់ខ្លួន និងអំពីលទ្ធផលនៃកិច្ចប្រជុំនានាពាក់ព័ន្ធនឹងកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ ជូននាយករដ្ឋមន្ត្រី-ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជ្រាប និងផ្តល់ការណែនាំ។

**មាត្រា ៣.-**

អ្នកសម្របសម្រួលជាតិនៃកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ និងជាប្រធានលេខាធិការដ្ឋានជាតិមហាអនុតំបន់មេគង្គ មានភារកិច្ចដូចតទៅ÷

ក. ទទួលខុសត្រូវក្នុងការសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការអនុវត្តគម្រោងក្នុងក្របខណ្ឌកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ។

ខ. ដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមក្នុងកិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីមហាអនុតំបន់មេគង្គ និងកិច្ចប្រជុំពាក់ព័ន្ធ និងការរៀបចំកិច្ចប្រជុំកំពូលមហាអនុតំបន់មេគង្គ។

គ. ដឹកនាំលេខាធិការដ្ឋានជាតិមហាអនុតំបន់មេគង្គដែលជាស្ថាប័ន "ច្រកចេញ-ចូលតែមួយ" សម្រាប់កិច្ចសហប្រតិបត្តិការនៅក្នុងក្របខណ្ឌកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ ដើម្បីជួយដល់រដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ ក្នុងការបំពេញភារកិច្ចដូចមានចែងខាងលើ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ អ្នកសម្របសម្រួលជាតិនៃកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ និងលេខាធិការដ្ឋានជាតិមហាអនុតំបន់មេគង្គ មានសិទ្ធិប្រើប្រាស់ត្រានិងថវិការបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី គ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ